ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលបានវិញ្ញាបនបត្រទទួលស្គាល់ ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា ធនាគារ អេស៊ីលីដា បានទទួលវិញ្ញាបនបត្រទទួលស្គាល់ **ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ** ពីនិយ័តករមូលបត្រកម្ពុជា (“ន.ម.ក.”)។ **ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ** គឺជាសេវាកម្មថ្មីមួយរបស់ធនាគារ អេស៊ីលីដា ក្នុងការផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។ សេវាកម្មនេះផ្តល់ជូនវិនិយោគិនទាំងក្នុង និងក្រៅប្រទេសនូវអត្ថប្រយោជន៍សំខាន់ៗ គឺ ដើម្បីវិនិយោគលើវិស័យមូលបត្រនៅផ្សារមូលបត្រកម្ពុជា (“ផ.ម.ក.”) ដើម្បីទទួលបាននូវសេវាថែរក្សាសុវត្ថិភាពប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាពខ្ពស់ ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងការចាត់ចែងសាច់ប្រាក់ និងមូលបត្រតាមតម្រូវការក្នុងវិស័យមូលបត្រ និងដើម្បីទទួលបានជម្រើសផ្សេងៗ ក្នុងការប្រើប្រាស់សេវាធនាគារ និងហិរញ្ញវត្ថុផ្សេងៗ ទៀត។

មុខងារចម្បងៗ របស់ **សេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ** រួមមាន គណនីរក្សាសុវត្ថិភាពសាច់ប្រាក់ គណនីរក្សាសុវត្ថិភាពមូលបត្រ និងសេវាភ្នាក់ងាររក្សាសុវត្ថិភាពមូលបត្រ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP